# អំពីរបៀបវិធីនិយាយអំពីទ្រង់ទ្រាយចក្រវាល

# និងវិជ្ជាដែលពោលពីច្បាប់ត្រួតត្រាចក្រវាល

**ចក្រវាលវិជ្ជា** ជាវិជ្ជាមួយនិយាយអំពីដើមកំណើតនៃចក្រវាឡ ។ បណ្ដាប្រជាជនដែលបានដល់នូវសេចក្ដីចម្រើនខ្លះហើយ បាននាំគ្នាយកចិត្តទុកដាក់នឹងប្រស្នានេះ ហើយរបៀបរៀបចំនៃការកសាងចក្រវាឡ ក៏បែបផ្សេង ៗ គ្នា សឹងប្រព្រឹត្តទៅតាមជំនឿរបស់ប្រជាជនក្នុងសម័យនោះ ។

តាមពួកពុទ្ធសាសនិកជន ( អក្សរសាស្ត្រសំស្ក្រឹត ) ថា ការប្លែកផ្សេងនៃលោកនេះកើតមកអំពីកម្ម ចំណោះវិជ្ជាទំនងនេះគេហៅថា "ចក្រវាលវិជ្ជា" ជាវិជ្ជាដែលនិយាយពន្យល់អំពីដើមកំណើតនៃការកសាង និងសេចក្ដីវិនាសនៃលោកនេះ ។ តាមពួកសវ៌ស្តិវាទិនពោលថា មានលោក ២ គឺ

១– លោកជាទីរួបរួម ឬភាជនលោក

២– លោកជាទីនៅនៃសត្វ និង មនុស្ស ឬសត្វលោក ។

ឯសត្វលោកនេះចែកចេញជា គឺ

១– សត្វឥតរូប ឬអរូបដែលមាននៅទីដទៃ ហើយមិនមាននៅក្នុងភាជនលោកទេ

២– សត្វមានរូប ឬរូបិននៅក្នុងចំណែកជាន់ខ្ពស់នៃរូបធាតុ

៣– ពួកសត្វដែលមានរូបនឹងរាងស្ដឹមស្ដែ នៅក្នុងលោកទាបៗ ចុះទៅក្រោមតាមក្រុមពួករបស់ខ្លួន ហើយជាសត្វបរិភោគកាមនៅក្នុងកាមធាតុ ។

ពួកសត្វលោកទាំងពួងបែកចេញជា ៥ ពួក ល្អ ២ ពួក អាក្រក់ ៣ ពួក ហៅថាគតិ ឬប្រភេទរបស់សង្សារវដ្ដ ។ ប្រភេទអស់នេះចែកចេញជាច្រើនពួកទៅទៀត គឺជាពួកទេវតាមាន ៣ ពួក ជាពួកមនុស្សមាន ៤ ពួក ជាពួកប្រេតមានតែមួយប្រភេទដូចជា សត្វតិរច្ឆាន

ទាំងឡាយ ឯសត្វដែលត្រូវមានទោស ( សត្វនរក ) ចែកចេញជា ៨ ប្រភេទ ត្រូវជាជាន់កាមធាតុមាន ២០ ប្រភេទ ឬ ២០ អន្លើ ។ គម្ពីរជាន់ក្រោយៗ មកកាន់តែមានរឿងរ៉ាវច្រើនៗ ឡើងជាងគម្ពីរជាន់ចាស់ ( គម្ពីរបាលី ) សឹងមានសេចក្ដីរោយរាយហើយសេចក្ដីអធិប្បាយពន្យល់អំពីវិជ្ជានេះ ក៏មានសេចក្ដីសំខាន់តែបន្តិចបន្តួចទេ ។

ឯរឿងរ៉ាវដែលគេបានឃើញក្នុងគម្ពីរបាលីចាស់ៗ ឡើងទៅមុនសម័យពុទ្ធកាលនោះ តាមគម្ពីរអស់នោះសំដែងថា ធាតុមាន ៤ ប្រភេទ ឬដែលហៅថា មហាភូតទាំង ៤ គឺ ទឹក ដី ភ្លើង ខ្យល់ ដែលផ្សំគ្នាជាភូតរូបឡើង ។ ( ដល់តមកគេបានបន្ថែម ) ធាតុទី ៥ មួយទៀត ហៅថា អាកាសធាតុ ។

ចក្រវាឡតូចៗ នោះជាចំណែកមួយ ដែលមានពោលទុកក្នុងភូមិសាស្ត្រជាន់ចាស់របស់តណ្ឌៀបុរាណ ថានៅកណ្ដាលពិភពនេះ មានភ្នំមេរុ ឬភ្នំព្រះសុមេរ៉ុ ។ នេះជាឈ្មោះភ្នំហិមាល័យ ព្រះអាទិត្យតែងគោចរនៅជុំវិញភ្នំនេះ ហើយនៅលើភ្នំអស់នេះ ជាទីស្ថិតនៅនៃពួកទេវតានៅខាងត្បូងភ្នំនេះ ជាទីតាំងនៃប្រទេសតណ្ឌៀ ឬជម្ពូទ្វីប នៅទិសដទៃជុំវិញភ្នំនេះ ក៏មានទ្វីបឯទៀតៗ ដែរ ។ តអំពីនោះទៅ ទើបដល់ទៅវាយុមណ្ឌលៈ ដែលមានពពកកកើតទៅជាទឹក ហើយបង្ហូរចុះនូវសមុទ្រទឹក – សមុទ្រមាស ។ សមុទ្រនេះកាលត្រូវខ្យល់បក់បោកកើតទៅជាអាបមណ្ឌល ហើយនៅលើនោះមានដីមាសអណ្ដែតឡើងដែលហៅថា កាញ្ចន-មណិភូមិ នៅលើផែនដីនោះមហាមេឃតែងបង្អុរចុះនូវពេជ្រនីល ចិន្តា ដី ទឹក ដែក តែងមាននៅជុំវិញភ្នំព្រះសុមេរ៉ុ ហើយមានភ្នំទាំង ៨ ដាច់ឃ្លាតចេញពីគ្នាដោយមហាសមុទ្រនឹងកោះទាំងឡាយ ។ ទ្វីបទាំងឡាយទើបកើតមានដីល្អដីជាតិតាំងនៅលើដីមាស ឬបរិវេណមាស ។

នៅទិសខាងកើតមានបុព្វវិទេហទ្វីប ជាទ្វីបកុះករដោយទីក្រុង និងស្រុកភូមិណែនណាន់តាន់តាប់ ពួកដែលនៅលើទ្វីបនេះមានអាយុ ២៥០ ឆ្នាំ ហើយទម្រង់មុខរបស់មនុស្សនៅទ្វីបនេះ ដូចទ្រង់ទ្រាយទ្វីបរបស់ខ្លួន គឺទម្រង់ខែ ១ ចំហៀង ។

នៅទិសខាងត្បូងមានជម្ពូទ្វីប ។ នេះជាទីកើតនៃព្រះពុទ្ធជាម្ចាស់ មនុស្សទាំងឡាយនៅលើទ្វីបនេះមានអាយុមិនហួសពី ១០០ ឆ្នាំទេ ។

នៅទិសខាងលិច មានអបរគោទានទ្វីប ។ នេះនៅចំណែកទិសខាងលិច ឯមនុស្សទាំងឡាយនៅក្នុងទ្វីបនេះមានអាយុ ៥០០ ឆ្នាំ ។

នៅទិសខាងជើងមានឧត្តរកុរុទ្វីប ។ នេះមិនមានទីក្រុង មិនមានស្រុកភូមិ មនុស្សទាំងឡាយនៅក្នុងទ្វីបនេះមានអាយុ ២០០០ ឆ្នាំ ។

ឯស្ថាននរកដែលមានភ្លើងឆេះជានិច្ច នៅឆ្ងាយអំពីខាងត្បូងបំផុតនៃជម្ពូទ្វីប រាប់ដោយចំនួនជាច្រើនលានគីឡូម៉ែត្រ ។ រណ្តៅនរកអអវិចីនោះ នៅទិសខាងត្បូងផុត ហើយនៅខាងលើនរកនេះមាននរក ៧ អន្លើទៀតហៅថា សញ្ជីវនរក នៅទីនេះមានខ្យល់បក់មកត្រូវសត្វដែលស្លាប់ទៅ ឲ្យមានជីវិតរស់ឡើងវិញ មានខ្សែខ្មៅ ( កាឡសុត្ត ) សម្រាប់រឹតកាត់សត្វនរកឲ្យដាច់ជាកំណាត់ៗ សង្ឃាតនរកនៅក្នុងចន្លោះភ្នំដែលទង្គិចទង្គុកគ្នាជានិច្ច រោរុវនរកជាស្ថានដែលមានសត្វនរកស្រែកទ្រហោយំខ្លាំងឡើងទៅទៀត តាបណនរក ជាស្ថាននរកដែលមានកម្តៅរោលរាល បតាបននរក ជាកន្លែងដែលក្តៅខ្លាំងណាស់ ។

នៅមាននរករងា ៨ រណ្តៅទៀត នៅក្នុងទីងងឹតស្លុប នៅខាងលើស្ថាននរក ជាស្ថានពួកសត្វតិរច្ឆានដែលយើងបានឃើញនៅក្នុងស្ថានមនុស្សលោកនេះខ្លះដែរ តែមិនមាននៅក្នុងស្ថានទេវលោកសោះឡើយ ។

ឯពួកប្រេតរមែងមានពាសពេញក្នុងស្ថានមនុស្សលោក តែដោយច្រើននោះ ពួកប្រេតនៅក្នុងស្ថានយមលោកជាអាណាចក្រមួយមាន ៣៦ ខេត្រ ។ អាយុប្រេតនោះ ៥០០ ឆ្នាំ ហើយក្នុង ១ ថ្ងៃរបស់ប្រេតប្រហែល ៣០ ថ្ងៃក្នុងស្ថានមនុស្សលោក ។

ពួកអសុរនៅក្នុងគុហាបាតភ្នំព្រះសុមេរ៍ ក្រោមទឹកសមុទ្រទៅទៀតនៅទីនោះមានក្រុងធំ ៤ មានស្តេចសោយរាជ្យ ៤ អង្គដែរ ពួកអសុរច្រើនតែនាំគ្នាលើកទ័ពចេញពីពិភពខ្លួនឡើងទៅច្បាំងតទល់ពួកទេវតា ៣៣ អង្គ ( ស្ថានត្រៃត្រឹង្ស ) ពួកកងទ័ពអសុរនេះ មានពួកយក្ខជាទ័ពស្រួច ឯពួកយក្ខមួយពួកនៅក្រោមដី ( ស្ថានបាតាល ) ឯពួកយក្ខឯទៀតៗ នៅលើដី ។ ឯភ្នំព្រះសុមេរ៍នេះមានស្ថាន ៤ អន្លើ នៅលើស្ថានទី ៤ មានមហារាជ ៤ អង្គ ជា

ស្តេចប្រចាំទិសទាំង ៤ ទុកជាទេព្តាដែរ ហើយមហារាជទាំង ៤ អង្គនេះមានព្រះជន្ម ៥០០ ឆ្នាំ មួយថ្ងៃក្នុងស្ថាននេះជា ៥០ ឆ្នាំក្នុងស្ថានមនុស្ស ។

មហារាជមួយអង្គៗ នោះមានបរិវារជាចំនួនច្រើន សុទ្ធតែជាពួកភ្លេង ដែលហៅថា គន្ធព្វ ៗ មិនមែនជាពួកទេវតាទេ ។ នៅពាក់កណ្តាលផ្លូវដែលឡើងទៅភ្នំព្រះសុមេរុ៍ មានពួកទេវតារបស់ព្រះអាទិត្យព្រះចន្ទ្រ និងពពួកផ្កាយផ្សេងៗ នៅលើកំពូលភ្នំព្រះសុមេរុ៍ជាស្ថានតាវតឹង្ស ព្រះឥន្ទ្រជាស្តេចទេវតា សោយរាជ្យនៅលើស្ថាននេះ ទីក្រុងមានព្រះរាជវាំងជ័យ ។ ឯអាយុទេវតានៅស្ថាននេះកំណត់ ១០០០ ឆ្នាំ ហើយក្នុង ១ ថ្ងៃប្រហែល ១០០ ឆ្នាំ ស្ថានមនុស្ស ។ នៅមានស្ថានសួគ៌ ៤ ជាន់ទៀតជាស្ថានបរិភោគកាមគុណដែរ ។

ឯស្ថានព្រហ្មនោះ ជាទីកើតនៃពួកទេព្តា ដែលជាឧបបាតិកកំណើតសោយបីតិជាអាហារ ជាពួកទេព្តាមានពន្លឺរស្មីភ្លឺដោយខ្លួនឯង ។ នៅស្ថានព្រហ្មមាន ៤ ជាន់ ជាពួកព្រហ្ម ដែលហៅថា ពួករូបព្រហ្ម ។ ស្ថានអរូបព្រហ្មមានតែពួកព្រហ្មដែលមានតែវិញ្ញាណឥតរូប មាន ៤ ជាន់ដែរ ពួក ៣ ជាន់ដំបូងជាពួកវិញ្ញាណដ្ឋិតិ ជាន់ទី ៤ ជាពួកសត្តាវាស ។ នៅមានចក្រវាឡតូច ៗ ទៀតជាចំនួនរាប់សែនរាប់លានច្រើនលើសលន់គណនា ៕